## Asking "What is this?"



តើជនជាតិខ្មែរនិយាយថា នេះជាអ្វី? មែនទេ នៅពេលសួរអំពីវត្ថុដែលមិនស្គាល់?

ឧទាហរណ៍ក្នុងការសន្ទនាខាងក្រោម និយាយអំពី វចនានុក្រមអេឡិចត្រូនិច (មិនមានក្នុងរូបភាព)

១ ធារី៖ ពិសិដ្ឋ! ទៅណាហ្នឹង? ហើយកំពុងកាន់អីហ្នឹង?
ពិសិដ្ឋ៖ អូ ធារី! ស្គាល់វចនានុក្រមអេឡិចត្រូនិចអត់? ខ្ញុំផ្ញើគេទិញមកពីជប៉ុន។
ធារី៖ អត់ស្គាល់ផង។ សម្រាប់ធ្វើអីគេអាហ្នឹង?

២ ធារី៖ ពិសិដ្ឋ! កាន់អីនៅនឹងដៃហ្នឹង?
ពិសិដ្ឋ៖ វចនានុក្រមអេឡិចត្រូនិច ធារីស្គាល់អត់?
ធារី៖ ធ្លាប់តែឮគេនិយាយ តែអត់ដែលឃើញសោះ។ គេប្រើយ៉ាងម៉េចអាហ្នឹង?

៣ ធារី៖ ពិសិដ្ឋ! អីហ្នឹង?
ពិសិដ្ឋ៖ វចនានុក្រមអេឡិចត្រូនិចហ្នឹងណា!
ធារី៖ អូ! ខ្ញុំស្មានតែអីគេ។ វចនានុក្រមអេឡិចត្រូនិចសោះ។ មើលដំបូង / ពីចម្ងាយអត់ស្គាល់។

៤ ធារី៖ ពិសិដ្ឋ! អីគេហ្នឹង?
ពិសិដ្ឋ៖ អូ ធារី! ខ្ញុំអត់ដឹងដែរហ្នឹង! មើលទៅដូចកុំព្យូទ័រអីចឹង។ មានគេពឹងខ្ញុំឲ្យយកទៅឲ្យបងតារា
ធារី៖ អូ! តស់ទៅសួរបងតារាទាំងអស់គ្នាម៉ងអីចឹង!

| | |
|---|---|
| វត្ថុ | object, thing |
| ឧទាហរណ៍ | example |
| ការសន្ទនា | conversation |
| វចនានុក្រមអេឡិចត្រូនិច | electronic dictionary |
| ទៅណាហ្នឹង? | Where are you going? |
| កាន់អី[នៅនឹងដៃ]ហ្នឹង? | What are you holding [in your hand]? |
| អីហ្នឹង? / អីគេហ្នឹង? | What is this? |
| អាហ្នឹង | this thing, that thing (less polite, used in casual conversations) |
| សម្រាប់ធ្វើអីគេ? | What is it for? |
| ធ្លាប់តែឮគេនិយាយ | I've only heard about it |
| គេប្រើយ៉ាងម៉េចអាហ្នឹង | How is [it/this thing] used? |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ... ហ្នឹងណា ! | It’s just a ...! (speaker thinks the other should know this already) |
| ស្មានតែ A B សោះ | I thought it was A, but actually it’s B. |
| ស្មានតែអីគេ ! | I thought it was something else! |
| ពឹងឲ្យ + verb | to be asked to [verb] |
| ម៉ង | spoken form of តែម្តង = directly |

## Cultural notes

អីគេហ្នឹង ? គឺជាពាក្យប្រើញឹកញាប់ជាងគេក្នុងភាសានិយាយ ជំនួសឲ្យពាក្យ នេះជាអ្វី ? / នោះជាអ្វី ? ការសួរពីនេះពីនោះនៅពេលជួបគ្នាក៏ជាទម្លាប់នៃការគួរសមផងដែរ ក្រៅពីសួរសុខទុក្ខ ដូចជាសួរថា

— មកពីណាហ្នឹង ?
— ទៅណាហ្នឹង ?
— អីគេហ្នឹង ? ( ពេលឃើញមានរបស់នៅនឹងដៃ )
— មកទិញអីវ៉ាន់ ?
— ទិញអីបានខ្លះហើយ ? ( ពេលជួបគ្នានៅផ្សារ )

| | |
|---|---|
| អីគេ / អ្វី / អី | what? |
| មកពីណាហ្នឹង ? | Where are you coming from? / Where have you been? |
| អីវ៉ាន់ / របស់ | stuff, things |
| មកទិញអីវ៉ាន់ ? | Are you shopping? / Have you come [here] to do some shopping? |

## Additional dialogue

ពិសិដ្ឋ ៖ បងតារា មានគេផ្ញើរបស់មកឲ្យបង ។ អីគេហ្នឹង បង ?
តារា ៖ អូ អរគុណពិសិដ្ឋ ។ ហ្នឹងវចនានុក្រមអេឡិចត្រូនិច ។
ធារី ៖ វចនានុក្រមអេឡិចត្រូនិចហ្នឹង អីគេ បង ?
តារា ៖ ដូចវចនានុក្រមសៀវភៅធម្មតាអីចឹង គ្រាន់តែយើងអាចរកពាក្យបានលឿន ហើយអាចដាក់វចនានុក្រមផ្សេងៗក្នុងហ្នឹងជាមួយគ្នាតែម្តង ។
ធារី ៖ អូ! ចុះអានោះអីគេហ្នឹង បង ?
តារា ៖ ប៊ិចសម្រាប់សរសេរលើអេក្រង់របស់វចនានុក្រម ។

| | |
|---|---|
| រកពាក្យ | to look up a word (in a dictionary) |
| ជាមួយគ្នាតែម្តង | all together; spoken form: ជាមួយគ្នាម៉ង |
| ចុះ ... | And what about ...? |
| អេក្រង់ | screen |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.